JICA កម្ពុជា

# គំរោងពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល

Project for Strengthening Human Resources Development System of Co-medical

ព្រឹត្តប័ត្រព័ត៌មានពីគំរោង JICA HRD    លេខ ២    ខែសីហា ឆ្នាំ ២០១០

## ពិធីប្រជុំផ្សព្វផ្សាយពីការបើកគំរោង

ពិធីប្រជុំផ្សព្វផ្សាយពីការបើកគំរោង បានប្រព្រឹត្តទៅនៅក្រសួងសុខាភិបាល កាលពីថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសំនាក់ឯកឧត្តមសាស្ត្រាចារ្យ អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល វត្តមានឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាលទទួលបន្ទុកផ្នែកបណ្តុះបណ្តាលមូលដ្ឋាន រួមទាំងវត្តមានមន្ត្រីមកពីនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និង មន្ត្រីមកពីនាយកដ្ឋាន ផ្សេងៗទៀតនៃទីស្តីការក្រសួងសុខាភិបាល។ គោលបំនងនៃពិធីប្រជុំផ្សព្វផ្សាយពីការបើកគំរោងនេះ គឺដើម្បីណែនាំអោយយល់ដឹងពីគំរោងផែនការទៅដល់នាយកដ្ឋានដែលពាក់ព័ន្ធទៅនឹងគំរោង នៅក្នុងក្រសួងសុខាភិបាល។ ទោះបីជាភាគីដៃគូនៃគំរោង ស្ថិតនៅក្នុង នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាលក៏ដោយ គំរោងមានទិសដៅក្នុងការបង្កើតច្បាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍន៍ធនធានមនុស្សដោយសហការណ៍ជាមួយនាយកដ្ឋានដទៃទៀត ។ ជាកិច្ចបញ្ចប់នៃពិធី គំរោងសង្ឃឹមយ៉ាងមុតមាំថាការប្រជុំនេះជាឱកាសដ៏ល្អនៃការចាប់ផ្តើម និងការណែនាំអោយ ស្គាល់ពីគំរោង ដែលនឹងជួយសំរួលដល់ដំនើរការអោយមានភាពរលូនទៅមុខ។





ខាងឆ្វេង លោក Kobayashi អនុប្រធានតំនាងការិយាល័យJICA ប្រចាំនៅកម្ពុជា ខាងស្តាំ ឯកឧត្តមសាស្ត្រាចារ្យ អេង ហួត រដ្ឋលេខាធិកាក្រសួងសុខាភិបាល

## ការស្វាគមន៍ចំពោះក្រុមការងារភាគីគំរោងសំរាប់ដំនើរទស្សនកិច្ចសិក្សានៅប្រទេសជប៉ុន

ក្រុមភាគីគំរោងដែលរួមមានវត្តមាន ឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិកាក្រសួងសុខាភិបាល ឯកឧត្តមសាស្ត្រាចារ្យ អ៊ុំ សុផល សកលវិទ្យាធិការនៃសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និង លោកស្រីឱសថការី គាត ភួង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល បានធ្វើទស្សនកិច្ចនៅប្រទេស ជប៉ុន ពីថ្ងៃទី ៣០ខែតុលា ដល់ថ្ងៃទី ៣ខែកញ្ញា ឆ្នាំ ២០១០។ ក្នុងដំនើរទស្សនកិច្ចសិក្សានេះ ក្រុមការងារ គំរោងបានទៅទស្សនានៅក្រសួងការងារ និង សុខមាលភាពសង្គម សកលវិទ្យាល័យជាតិថៃទាំវេជ្ជសាស្ត្រ និង មជ្ឈមណ្ឌលជាតិ សុខភាពពិភពលោក ។ លើសពីនេះទៅទៀត ក្រុមការងារក៏បានធ្វើការ សិក្សាអំពីប្រព័ន្ធបណ្តុះបណ្តាលគ្រូ បង្រៀន នៅសាលាផ្នែកវេជ្ជសាស្ត្រ និង ផ្នែកអមវេជ្ជសាស្ត្រ និង ដំនើរការអភិវឌ្ឍន៍ និង ការគ្រប់គ្រង មូលដ្ឋាន ច្បាប់សំរាប់ការអភិវឌ្ឍន៍ធនធានមនុស្ស។ គួរបញ្ជាក់ផងដែរថា មុនពេលដំនើរទស្សនកិច្ចនៅ ប្រទេសជប៉ុន នៅថ្ងៃ ២៥ ខែសីហា ក្រុមការងារបានចូល រួមក្នុងការ ប្រជុំធ្វើបទបង្ហាញខ្លះៗពីប្រវត្តិនៃប្រព័ន្ធសុខាភិបាលនៅប្រទេសជប៉ុន ដោយលោកស្រីវេជ្ជ. Noriko ប្រធានទីប្រឹក្សាគំរោង។ រួចមកគាត់ ក៏បានពន្យល់អំពីច្បាប់មូលដ្ឋាន សំរាប់ពង្រឹងការអភិវឌ្ឍន៍ធនធានមនុស្ស។



ពីខាងឆ្វេង ឯកឧត្តមសាស្ត្រាចារ្យ អ៊ុំ សុផល
ឯកឧត្តមសាស្ត្រាចារ្យធា គ្រុយ
លោកស្រីឱសថ គាត ភួង និង
លោកស្រីវេជ្ជ. Noriko

# ការចាកចេញរបស់លោកស្រីវេជ្ជបណ្ឌិត Noriko ពីប្រទេសកម្ពុជា

លោកស្រីវេជ្ជបណ្ឌិត Noriko ជាប្រធានទីប្រឹក្សាគំរោង ប៉ុន្តែគាត់មិនអាចស្នាក់ នៅអចិន្ត្រៃយ៍នៅកម្ពុជាបានឡើយ។ គាត់នឹងមកបំរើការងារជាអ្នកជំនាញការរយៈពេលខ្លីនៅកម្ពុជា ២ ទៅ ៣ដងក្នុងមួយ ឆ្នាំ។ គាត់បាន បំពេញបេសកម្មលើកទី១ របស់គាត់ ហើយបានចាកចេញពីប្រទេសកម្ពុជា នៅថ្ងៃទី២៧ ខែសីហា។ ខាងក្រោម នេះ គឺជាសារ របស់លោកស្រីវេជ្ជបណ្ឌិត Noriko :

គំរោងនេះឈរលើមូលដ្ឋានគ្រឹះ ២ គឺទី១ "ពង្រឹងប្រព័ន្ធ បណ្តុះបណ្តាលសំរាប់ គ្រូបង្រៀនដែលមានស្រាប់ និង គ្រូបង្រៀនថ្មី" និង ១ ទៀតគឺ "គាំទ្រការអភិវឌ្ឍន៍ប្រព័ន្ធ ច្បាប់ សំរាប់ បុគ្គលិក-សុខាភិបាល"។ ក្នុងរយៈពេល ២ខែ នៃការ-ចាប់ផ្តើមដំបូងនៃគំរោង ក្រុមការងារគំរោងមានសកម្មភាព មមាញឹកជា ច្រើនដូចជា : ការបើក-ការិយាល័យគំរោង ការជ្រើសរើសបុគ្គលិក ការកំនត់ពេលសំរាប់ការប្រជុំទៀងទាត់ និង ការពិ-ភាក្សាអំពីការអនុវត្តន៍នៃគំរោង មុខងារ និង ភារ-កិច្ចក្នុង ចំនោមសមាជិកក្នុងក្រុមគំរោង។ ក្រៅពីសកម្មភាពទាំងនោះ ក្រុមការងារគំរោងក៏បានជួបជាមួយនឹងមន្ត្រី ដែលជាប់ពាក់ព័ន្ធទាំងក្នុង និងក្រៅក្រសួងសុខាភិបាល ហើយថែមទាំងបាន ធ្វើ-ការប្រជុំផ្សព្វផ្សាយ ពីការបើកគំរោងទៀតផង។

រាល់ភាគីដែលជាប់ពាក់ព័ន្ធនឹងគំរោងបានយល់ច្បាស់ អំពីសារៈសំខាន់នៃការកសាងសមត្ថភាពគ្រូបង្រៀននៅផ្នែកអមវេជ្ជសាស្ត្រដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពនៃប្រព័ន្ធអប់រំសំរាប់បុគ្គលិកសុខាភិបាល និង ការបង្កើតនូវប្រព័ន្ធបណ្តុះបណ្តាលសំរាប់ គ្រូបង្រៀនដោយឈរលើទស្សនៈវិស័យយូរអង្វែង។

ជាការចាប់ផ្តើមនៃគំរោង ក្រុមការងារគំរោងបានធ្វើការប្រមូលព័ត៌មានដែលជាមូលដ្ឋានគ្រឹះទាក់ទងនឹងប្រព័ន្ធអប់រំ ផ្នែកគិលានុបដ្ឋាក និងឆ្មប ពីសកម្មភាពនៃគំរោងពីមុនមក ។ នាពេលបច្ចុប្បន្ននេះ នៅប្រទេសកម្ពុជាមានម្ចាស់ជំនួយអន្តរជាតិជាច្រើន ដែលកំពុងអនុវត្តន៍នូវសកម្មភាពរៀងៗខ្លួន។ ដូច្នេះការសំរបសំរួល ជាមួយម្ចាស់ជំនួយនៅក្នុងក្រសួងសុខាភិបាល មានសារៈសំខាន់ណាស់ ដែលក្នុងពេលនេះ ក្រុមការងារគំរោង កំពុងប្រមូលព័ត៌មានទាក់ទិននឹងប្រព័ន្ធសំរបសំរួល នៃជំនួយទាំងនោះផងដែរ។

ប្រព័ន្ធផ្តល់វិញ្ញាប័នប័ត្រ និង ចុះបញ្ជីជាការផ្សារភ្ជាប់ ការបណ្តុះបណ្តាលផ្នែកសុខាភិបាល និងការរក្សាគុណភាពនៃសេវាកម្មសុខាភិបាល។ ដូច្នេះហើយក្រសួងសុខាភិបាលមានបំនងចង់បង្កើតនូវ ប្រព័ន្ធផ្តល់វិញ្ញាប័នប័ត្រ អោយបានឆាប់ៗដើម្បីធានាអោយមាននូវគុណភាពសេវាកម្ម



**ខាងឆ្វេងគឺ លោកស្រីវេជ្ជ. Noriko ខាងស្តាំ លោកវេជ្ជ. ភុំ សំសុង អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស**

សុខាភិបាល ក្នុងនាមជាសមាជិកនៃអាស៊ាន។ ប្រព័ន្ធផ្តល់វិញ្ញាប័នប័ត្រ មិនអាចបង្កើតទៅបានបើគ្មានច្បាប់ជាមូលដ្ឋានគ្រឹះនៃបុគ្គលិកសុខាភិបាល។ ដូច្នេះហើយទើបក្រុមការងារគំរោងចាប់ផ្តើម ប្រមូលព័ត៌មានដែលមាន បទបញ្ញត្តិ និងច្បាប់ ទាក់ទងនឹងការអភិវឌ្ឍន៍បុគ្គលិកសុខាភិបាលដើម្បីធ្វើការវិនិច្ឆ័យស៊ីជំរៅអំពីការចូលរួមចំនែករបស់គំរោងក្នុងរយៈពេល៥ឆ្នាំ។ ដូចបានរៀបរាប់មកខាងលើនេះ ក្រុមការងារគំរោងកំពុងនឹងប្រមូលព័ត៌មាន ក៏ដូចជាកំពុង ពិភាក្សា អំពីការធ្វើបែបផែន នៃសកម្មភាព គំរោងសំរាប់បង្កើត អោយ-មាននូវប្រព័ន្ធបណ្តុះបណ្តាល គ្រូបង្រៀនផ្នែក-សុខាភិបាល និង ប្រព័ន្ធច្បាប់។

"នេះជាលើកទីមួយរបស់ខ្ញុំដែលធ្វើការជាមួយ លោកស្រីវេជ្ជ. Noriko។ ខ្ញុំមានការស្ញប់ស្ញែងចំពោះភាពមោះមុតនិង ស្វាហាប់ ចំពោះការងាររបស់លោកស្រីវេជ្ជ. Noriko ដែលផ្អែកលើ មិត្តភាព យូរអង្វែង និង អាស្រ័យភាពជាមួយប្រជាជនកម្ពុជា និង លើបទពិសោធន៍ដ៏ គួរអោយកើតសរសើររបស់គាត់នៅប្រទេស អាកានីស្ថាន និង អាហ្វ្រិច។ អរគុណចំពោះការធ្វើអោយគំរោងនេះមានដំនើរទៅមុខយ៉ាងរហ័សក្នុងរយៈពេល២ខែនេះ។"



**វិចារណកថារបស់ អ្នកសំរបសំរួលគំរោង**